# តើអ្នកដឹងទេ?

## 1 - *វិសាលភាព និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស*

*អំពើជួញដូរមនុស្ស បានបំផ្លាញដល់សន្តិសុខមនុស្សជាតិ ដោយការកេងប្រវ័ញ្ច និង រំលោភបំពានលើសិទ្ធិ អាយុជីវិត កិត្តិយស សេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលជាជនរងគ្រោះ ក្រុមគ្រួសារ និងសង្គមជាតិ ។*

*ជនល្មើសជួញដូរមនុស្សកេងយកផលប្រយោជន៍ពីជនរងគ្រោះ ដោយចាត់ទុកថា " ជាទំនិញ និងជាទាសករសម័យទំនើប " ដោយមិនគិតពីទុក្ខវេទនា និងការខាតបង់របស់ជនរងគ្រោះ ។*

*ពលរដ្ឋមួយចំនួន ទាំងបុរស ស្ត្រី យុវវ័យ និងកុមារក្លាយជាជនរងគ្រោះ ដោយសារតែបានជឿលង់តាមការសន្យាផ្តល់ផលប្រយោជន៍ ការលួងលោម ឬបង្ខិតបង្ខំ តាមគ្រប់មធ្យោបាយ របស់មេខ្យល់ ព្រមទាំងការអូសទាញផ្សេងទៀត ដោយមិនបានដឹងថា ខ្លួនកំពុងតែចូលក្នុងសំណាញ់របស់ឧក្រិដ្ឋជន ពិបាកនឹងដកថយក្រោយ ។*

*ពលករជាច្រើន បានចេញទៅរកការងារធ្វើ និងយុវនារីខ្លះស្វែងរកគូស្រករនៅក្រៅប្រទេសតាមរយៈមេខ្យល់ ឬមិត្តភក្តិ តែត្រូវបានគេជួញដូរ ធ្វើទណ្ឌកម្ម ប្រមាថមាក់ងាយ មិនបានអ្វីក្រៅពី ខាតបង់ទ្រព្យសម្បត្តិ ពេលវេលា កិត្តិយស សេចក្តីថ្លៃថ្នូរ ខ្លះធ្លាក់ខ្លួនពិការ មានជម្ងឺរ៉ាំរ៉ៃ ញៀនថ្នាំ មានផ្ទៃពោះដោយគ្មានការទទួលខុសត្រូវ និងខ្លះបានបាត់បង់ជីវិត ។*

## 2 - *តើ "ការជួញដូរមនុស្ស" ជាអ្វី?*

*គឺជា ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬការប្រើកម្លាំង ឬការបង្ខិតបង្ខំតាមរូបភាពផ្សេងៗ ដូចជា ការចាប់ពង្រត់ ការក្លែងបន្លំ ការបោក បញ្ឆោត ការរំលោភលើអំណាច ឬតួនាទីទៅលើជនដែលងាយទទួលរងគ្រោះ ឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកម្រៃ ផ្សេងៗ ដើម្បីឲ្យមានការយល់ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀត ក្នុងគោលបំណងដើម្បីធ្វើការ "កេងប្រវ័ញ្ច"។*

***ការកេងប្រវ័ញ្ច៖*** *ត្រូវរាប់បញ្ចូលជាអប្បបរមានូវ ការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទតាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬសេវាកម្មទាសភាព*

ឬការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងទាសភាព ភាពជាអ្នកបម្រើជាប់ថ្លៃ ឬការដកហូតសរីរាង្គ ជាដើម ។

ប្រសិនបើមធ្យោបាយណាមួយ ដែលមានចែងក្នុងវាក្យខ័ណ្ឌ (a) នៃមាត្រានេះ ត្រូវបានយកមកប្រើ ដោយជនជួញដូរមនុស្ស ដើម្បីកេងប្រវ័ញ្ច ទោះបីជាមានការយល់ព្រមពីជនរងគ្រោះក៏ដោយ ក៏ការយល់ព្រមនេះមិនអាចយកជាការបានឡើយ ។

ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកកុមារក្នុងគោល បំណងធ្វើអាជីវកម្ម ត្រូវចាត់ទុកថាជា "ការជួញដូរមនុស្ស" ទោះបីជាអំពើនេះមិនជាប់ពាក់ព័ន្ធទៅនឹងមធ្យោបាយណាមួយ ដែលមានចែងក្នុងវាក្យ ខ័ណ្ឌ (a) នៃមាត្រានេះក៏ដោយ។

**"កុមារ" មានន័យថាមនុស្សណាម្នាក់ ដែលមានអាយុក្រោម១៨ឆ្នាំ ។**

**3 - ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា**

ព្រះរាជាណាចក្រកម្ពុជា មានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការពារអនីតិជន ដែលបានអនុម័ត និងប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ ដោយព្រះរាជក្រម លេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលកំណត់ការដាក់ទោសទណ្ឌធ្ងន់ធ្ងរលើជនជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ និងអ្នកសមគំនិត ជាពិសេសដែលបានប្រព្រឹត្តទៅលើកុមារ (អនីតិជន)។

យន្តការជាតិដែលត្រូវបានបង្កើតឡើង គឺ «គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៖ គ.ជ.ប.ជ» មាន២២ក្រសួង ស្ថាប័នចូលរួម ដឹកនាំដោយ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានអគ្គលេខាធិការដ្ឋានមួយ ចំណុះក្រសួងមហាផ្ទៃ ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ និងមានអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរង មួយចំនួន ។

**គ.ជ.ប.ជ មាន៦ ក្រុមការងារអន្តរក្រសួងស្ថាប័ន :**

១-ក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយ ក្រសួងអប់រំ យុវជន និងកីឡា។

២-ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៣-ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ។

៤-ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌។

៥-ក្រុមការងារទេសន្តរប្រវេសន៍ដឹកនាំដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

៦-ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយ ក្រសួងកិច្ចការនារី។

ផែនការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ ២០១៤-២០១៨ ត្រូវបាន និងកំពុងអនុវត្តនៅថ្នាក់ក្រោមជាតិ មានគណៈកម្មាធិការថ្នាក់ក្រោមជាតិ ដែលហៅថា គណៈកម្មាធិការរាជធានី ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ) ដឹកនាំដោយ អភិបាលរាជធានី គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ដឹកនាំដោយអភិបាលខេត្ត និងមានរចនាសម្ព័ន្ធរហូតដល់ឃុំសង្កាត់ ទូទាំងប្រទេស ។

គ្រប់ករណី ដែលអ្នកសង្ស័យថាជាអំពើជួញដូរមនុស្ស៖ ជួញដូរពលកម្ម ឬជួញដូរផ្លូវភេទ ជាពិសេសលើស្ត្រី និងកុមារ សូមរាយការណ៍ទៅបណ្តាញនៃរចនាសម្ព័ន្ធគណៈកម្មាធិការជាតិគ្រប់ថ្នាក់ ឬតាមលេខទូរស័ព្ទ ១២៨៨ ឬ ០២៣ ៩៩៧៩១៩ ។